# គំរោងយុត្តិធម៌ មេសា ២០០៦

*អង្គជំនុំជំរះវិសាមញ្ញ : យុត្តិធម៌សំរាប់ជនរងគ្រោះនៃរបបខ្មែរក្រហម*


**បុព្វកថា**
ដោយលោក James A. Goldston ១

**ប្រវត្តិសាស្ត្រ**
ប្រវត្តិសាស្ត្រនយោបាយនៃអង្គជំនុំជំរះវិសាមញ្ញ
ដោយ Craig Etcheson ៧

**ទស្សនវិស័យ**
រាជរដ្ឋាភិបាលកម្ពុជា
ដោយ ឯកឧត្តម សុខ អាន ២៥
អង្គការឃ្លាំមើលសិទ្ធិមនុស្ស
ដោយ Dinah PoKempner ៣៣
រឿងរ៉ាវផ្ទាល់ខ្លួន
ដោយ សុជាតា ពៅ ៤៩

**តួអង្គ**
ជនជាប់ចោទ ៥៥
ដោយ Steve Heder
ជនរងគ្រោះ និងសាក្សី ៦៣
ដោយ Susana SáCouto
ការស៊ើបអង្កេត និងការចោទប្រកាន់ ៧៥
ដោយ Kelly Dwan Askin

**បញ្ហានានា**
ការផ្តន្ទាទោសអំពើប្រល័យពូជសាសន៍
ដោយ Patricia M. Wald ៨៧
ការបញ្ចូលគ្នាយុត្តិធម៌អន្តរជាតិ និង យុត្តិធម៌ជាតិ
ដោយ Caitlin Reiger ១០១
ផលប៉ះពាល់មកលើតុលាការ និងសង្គមកម្ពុជា
បទសម្ភាសជាមួយ លោក ធន សារ៉ាយ
លោក សន់ ឆៃ និង លោក អ៊ុក វ៉ាន់ដេត ១១៣
ការផ្សព្វផ្សាយ : មូលដ្ឋានដើម្បីជោគជ័យ
ដោយ Tracey Gurd ១២៣
ការសំខាន់នៃការតាមដានសង្កេត
ដោយ Richard J. Rogers ១៣៩

**ដំណោះស្រាយ**
យន្តការយុត្តិធម៌អន្តរកាល
ដោយ Laura McGrew ១៥១
ការសាងយុត្តិធម៌ឡើងវិញ
ដោយ Kek Galabru ១៦៥


## អង្គជំនុំជំរះវិសាមញ្ញ

៣០ ឆ្នាំ ក្រោយខ្មែរក្រហមកាន់កាប់អំណាច និងការចរចារជាច្រើនឆ្នាំរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជាអង្គជំនុំជំរះវិសាមញ្ញចុងបញ្ចប់អាចរៀបចំតំណើរការកាត់ទោសមេដឹកនាំ និងអ្នកទទួលខុសត្រូវទាំងឡាយដែលនៅរស់សេសសល់បានហើយ។ ទាក់ទងនឹងតំណើរការនេះគំរោងយុត្តធម៌ពិនិត្យទៅលើអង្គជំនុំជំរះវិសាមញ្ញ និងបញ្ហានានាដើម្បីផ្តល់យុត្តធម៌ដល់ជនរងគ្រោះនៃរបបខ្មែរក្រហម។

## បុព្វកថា

### ជេម្ស អេ ហ្គូលស្តុន

សៀវភៅនេះ ជារបស់គំរោងផ្តួចផ្តើមយុត្តិធម៌ ផ្តោតទៅលើអង្គជំនុំជំរះវិសាមញ្ញនៅក្នុងតុលាការប្រទេសកម្ពុជាដែលជាការពិសោធន៏ខុសធម្មតានៅក្នុងយុត្តិធម៌អន្តរកាលដែលឈរលើព្រឹត្តិការណ៏ពិសេសនៃការនិទានប្រវត្តិសាស្ត្រពីរខុសគ្នាបើមិនជាន់គ្នាទេនោះ។ នៅក្នុងក៏រិតមួយអង្គជំនុំជំរះវិសាមញ្ញកត់សំគាល់ចំណុចសំខាន់នៅក្នុងបទពិសោធន៏ហិង្សានិងទុក្ខវេទនាដ៏ឈឺចាប់។ ទោះបីមិនពេញលេញក៏ដោយវាជាកិច្ចប្រឹងប្រែងហ្មឹងម៉ាត់ជាលើកដំបូងដើម្បីយកច្បាប់មកអនុវត្តលើឧក្រិដ្ឋកម្មប្រព្រឹត្តដោយខ្មែរក្រហមជាងមួយភាគបួននៃសតវត្សកន្លងមក។ ក្នុងពេលជាមួយគ្នានេះអង្គជំនុំជំរះវិសាមញ្ញជាតុលាការក្រោយគេក្នុងបណ្តានៃសាលាជំរះក្តីដែលមានតរៀងមកដែលចាប់ផ្តើមពី នួរិនប៊ែរ ហើយរហូតដល់ការបង្កើតថ្មីៗនេះនូវតុលាការព្រហ្មទណ្ឌអន្តរជាតិដែលមានបំណងធានាឱ្យបានការទទួលខុសត្រូវផ្នែកច្បាប់ចំពោះអំពើយង់ឃ្នងទៅលើមហាជន។

អត្ថប្រយោជន៍ជាសក្ខានុភូតដែលបានរៀបរាប់ខាងលើសន្មតទុកជាមុនថាកម្មវិធីសង្កេតមើលការវិនិច្ឆ័យក្តីត្រូវបានបង្កើតឡើងដើម្បីការពារដំណើរការដ៏មានប្រសិទ្ធិភាពនៃអង្គជំនុំជំរះវិសាមញ្ញនិងរាយការណ៍យ៉ាងយកចិត្តទុកដាក់ ។កម្មវិធីដែលគ្រប់គ្រងមិនបានល្អប្រហែលជាឱ្យផលអាក្រក់ច្រើនជាងល្អ ។ កម្មវិធីសង្កេតការណ៍នីមួយៗត្រូវកំណត់គោលដៅឱ្យបានច្បាស់លាស់ ធានាថាវិធីសង្កេតការណ៍និងធ្វើរបាយការណ៍សមស្របតាមគោលដៅទាំងនោះពិតប្រាកដជានិច្ចឯករាជនិងមិនលំអៀង ហើយរហូតមកដល់ពេលនេះតាមលទ្ធភាពត្រូវបង្កើតឱ្យមានទំនាក់ទំនងការងារល្អជាមួយនឹងនាដការីពាក់ព័ន្ធនៅក្នុងអង្គជំនុំជំរះវិសាមញ្ញ ។ ថ្វីបើអ្នកសង្កេតការណ៍មិនអាចដោះស្រាយឱ្យបានទាំងស្រុងនូវជម្ងឺជាសក្ខានុភូតរបស់តុលាការ ឬសាលាក្តីក៏ដោយ ក៏អ្នកទាំងនោះបានផ្តល់វិភាគទានជាវិជ្ជមានដល់រដ្ឋបាលតុលាការនៅក្នុងយុត្តិការជាច្រើន ។ លទ្ធផលបែបនេះគួរឱ្យចង់បានណាស់នៅប្រទេសកម្ពុជា ។

---

*លោក Richard J. Roger ជាប្រធាននៃអង្គការសន្តិសុខនិងសហប្រតិបត្តិការអឺរ៉ូប ពិចារណាតួនាទីរបស់អ្នកសង្កេតការណ៍តុលាការ និងថែងពីករណីសំរាប់ការសង្កេតការណ៍ឯករាជនៅអង្គជំនុំជំរះវិសាមញ្ញ ។

[១] ការវិនិច្ឆ័យក្តីទាំងនេះត្រូវបានសង្កេតមើលដោយទីប្រឹក្សាដែលត្រូវបានជួលដោយការិយាល័យនៃអង្គការសន្តិសុខ និងសហប្រតិបត្តិការ អឺរ៉ូបនៅទីក្រុង Baku ប្រទេស Azerbaijan និងការិយាល័យសំរាប់ស្ថាប័នប្រជាធិបតេយ្យ និងសិទ្ធិមនុស្សនៃអង្គការសន្តិសុខ និងសហប្រតិបត្តិការអឺរ៉ូប ។ កម្មវិធីសង្កេតមើលការវិនិច្ឆ័យក្តីដែលត្រូវបានធ្វើឡើងរក្រោយពីការបោះឆ្នោតជ្រើសរើសប្រធានាធិបតីក្នុងខែ តុលា ឆ្នាំ ២០០៣ ដែលបង្កឱ្យមានជម្លោះហឹង្សានៅក្នុងក្រុង Baku រវាងកងកម្លាំងសន្តិសុខ និងក្រុមបាតុករដែលប្រឆាំងនឹងការលួចបន្លំសន្លឹកឆ្នោត ។ អំពើហឹង្សានេះបណ្តាសលឱ្យមានការឃុំខ្លួនមនុស្សចំនួន ៦០០ នាក់ហើយជារយថាហេតុមនុស្សចំនួន ១២៥នាក់ រួមទាំងមេដឹកនាំសំខាន់ៗរបស់គណៈបក្សប្រឆាំងផងត្រូវបានកាត់ទោស ។គ្រប់ការវិនិច្ឆ័យក្តីទាំងអស់ត្រូវបានសង្កេតមើលតាមកម្មវិធី ដើម្បីប៉ាន់ប្រមាណថាតើការវិនិច្ឆ័យក្តីទាំងនោះប្រតិបត្តិតាមកាតព្វកិច្ចអន្តរជាតិកំរិតណាដែរ ។ របាយការណ៍សន្និដ្ឋានថា ការវិនិច្ឆ័យក្តីមិនត្រូវបានធ្វើឡើងជាដរាបតាមវិធិដែលធានាឱ្យមានការអនុវត្តន៍យ៉ាងពេញលេញនូវស្តង់ដារអន្តរជាតិស្តីពីការវិនិច្ឆ័យក្តីដោយត្រឹមត្រូវយុត្តិធម៌នោះទេ ។ ចូរមើលរបាយការណ៍ស្តីពីកម្មវិធីសង្កេតមើលការវិនិច្ឆ័យក្តី/ការិយាល័យនៃអង្គការសន?សុខនិងសហប្រតិបត្តិការអឺរ៉ូបនៅទីក្រុង Baku ប្រទេស Azerbaijan: http://www.osce.org/publications/ordihr/2005/04/13762209 en.pdf.

[២] មជ្ឈមណ្ឌលសំរាប់ឯករាជភាពនៃចៅក្រមនិងមេធាវី/តុលាការយុត្តិធម៌អន្តរជាតិមានគោលបំណងលើកស្ទួយ និងការពារឯករាជភាព និងអព្យាក្រឹតភាពរបស់តុលាការ ។ ជាផ្នែកមួយនៃកម្មវិធីរបស់តុលាការយុត្តិធម៌អន្តរជាតិ កម្មវិធីនេះពិនិត្យមើលការវិនិច្ឆ័យក្តី និងចេញរបាយការណ៍សាធារណៈ ។ ឧទាហរណ៍ចូរមើលតុលាការយុត្តិធម៌អន្តរជាតិៈការវាយប្រហារទៅលើយុត្តិធម៌ៈ ការឃាឃីរំខាន និងការកាត់ទោសចៅក្រមនិងមេធាវី ឆ្នាំ ២០០៣ ។

[៣] លោកអគ្គលេខាធិការអង្គកាសហប្រជាជាតិ Kofi Annan ចាត់តាំង Dr. Hans Koechler នៃអង្គការរីកចំរើនអន្តរជាតិដែលមានមូលដ្ឋាននៅទីក្រុងវីយែនឱ្យសេង្កតការណ៍នៅ Camp Zeist បទេសហូល្លង់ក្នុងឆ្នាំ ២០០០ និង ២០០១ ។ លោក Koechler បានរិះគន់យ៉ាងខ្លាំងចំពោះការដឹកនាំការវិនិច្ឆ័យក្តីនិងសាលក្រមតុលការ ។ ចូរមើលរបាយការណ៍ស្តីពីនិងការវាយតម្លៃការកាត់ទោសនៅតុលាការ Lockerbie ដែលធ្វើឡើងដោយតុលាការពិសេសអេកូសនៅ Camp Zeist ប្រទេសហូល្លង់រៀបរៀងដោយ Dr. Hans Koechler ដែលជាសាស្ត្រចារ្យសកលវិទ្យាល័យ និងជាអ្នកសង្កេតការណ៍អន្តរជាតិនៃអង្គការរីកចំរើន អន្តរជាតិដែលបានទទួលការតែងតាំងពីលោកអគ្គលេខាធិការអង្គកាសហប្រជាជាតិ Kofi Annan តាមសេចក្តីសំរេច នៃក្រុមប្រឹក្សាសន្តិសុខ លេខ ១១៩២ ១៩៩៨ ថ្ងៃទី ៣ ខែកុម្ភៈ ឆ្នាំ ២០០១ និងរបាយការណ៍ស្តីពីដំណើរការក្តីបណ្តឹងឧទ្ធរណ៍ នៅតុលាការអេកូសប្រទេសហូល្លង់ តុលាការ Lockerbie នៅក្នុងរឿងក្តី Abdelbaset Ali Mohamet Al Megrahi v. H. M ។

គាំទ្រដោយលោកសាស្ត្រាចារ្យ Hans Koechler ដែលជាអ្នកសង្កេតការណ៍អន្តរជាតិនៃអង្គការរីកចំរើនអន្តរជាតិ ដែលបានទទួលការចាត់តាំងពីលោកអគ្គលេខាធិការអង្គការសហប្រជាជាតិ Kofi Annan តាមសេចក្តីសំរេចនៃក្រុមប្រឹក្សាសន្តិសុខលេខ ១១៩២ ១៩៩៨ ថ្ងៃទី ២៦ ខែមិនា ឆ្នាំ ២០០១ របាយការណ៍ទាំងពីរនេះអាចមាននៅ http://i-p-o.org/ lockerbie _observer_ mission.htm.

[៤] នីតិរដ្ឋនិងយុត្តិធម៌អន្តរកាលនៅក្នុងសង្គមកំពុងមានជម្លោះ និងនៅក្នុងរយៈពេលក្រោយជម្លោះរបាយការណ៍នៃលោកអគ្គលេខាធិការ អង្គកាសហប្រជាជាតិ UN. DOc S/2004 ថ្ងៃទី ២៣ ខែសិហា ឆ្នាំ ២០០៤ កឋាខ័ណ្ឌ ១២។

[៥] របាយការណ៍ដោយ Dr. Hans Koechler ស្តីពីការវិនិច្ឆ័យក្តីនៅតុលាការ Lockerbie គឺជាឧទាហរណ៍មួយនៅពេលដែលការរកឃើញផ្នែកសាច់ច្បាប់មានន័យថាការប៉ាន់ប្រមាណអំពីភស្តុតាងត្រូវបានរិះគន់

របាយការណ៍ស្តីពីការសង្កេតមើលការវិនិច្ឆ័យក្តីអាចធ្វើតាមរចនាបថប្រហាក់ប្រហែលគ្នាទៅនឹងសេចក្តីស្នើសុំផ្នែកច្បាប់ ឬសេចក្តីសំរេចរបស់តុលាការ។ ហេតុដូច្នេះហើយ ចំពោះបញ្ហានីមួយៗរបាយការណ៍អាចរួមមាន: សេចក្តីផ្តើមដែលចែងថាតើបញ្ញត្តិស្តីពី ការវិនិច្ឆ័ក្តីដោយត្រឹមត្រូវយុត្តិធម៌ណាមួយដែលត្រូវបានបំពាន និងដោយតុលាការណាដែរ ការពន្យល់បំភ្លឺអំពីច្បាប់ក្នុងស្រុកនិងច្បាប់អន្តរជាតិពាក់ព័ន្ធដែលអាចអនុវត្តបាន សេចក្តីសង្ខេបអំពីអង្គហេតុនៃរឿងក្តីដែលនាំឱ្យមានកង្វល់ការវិភាគដែលនៅក្នុងនោះអង្គហេតុត្រូវបានអនុវត្ត ចំពោះច្បាប់ និងនៅទីបញ្ចប់អនុសាសន៍ស្តីពីសកម្មភាពដែលស្នើឡើង។ ប្រភេទនៃរបាយការណ៍ ដែលជាបែបផែនចេញដោយកម្មវិធី សង្កេតមើលការវិនិច្ឆ័យក្តី រួមមាន:

- របាយការណ៍ដែលគូសបញ្ជាក់ពីសាលក្រមដោយឡែកណាមួយដែលចេញដោយតុលាការ ដែលគេគិតថា បានបំពានទៅលើបញ្ញត្តិស្តីពីការវិនិច្ឆ័វិនិច្ឆ័ក្តីដោយត្រឹមត្រូវយុត្តិធម៌ឧទាហរណ៍ដូចជានៅពេលដែលតុលាការធ្វើសេចក្តីបណ្តេញ សាធារណជនចេញពីតុលាការដោយគ្មានហេតុសំអាងសុពល។ របាយការណ៍ស្តីពីបញ្ហាតែមួយ/តុលាការតែមួយបែបនេះជាទូទៅមានទំហំខ្លីដោយប្រៀបមួយ ឬពីរទំព័រប៉ុណ្ណោះ។

- បាយការណ៍ដែលវិភាគពីកង្វល់ផ្នែកវិធាននីតិវិធីដែលបានសង្កេតមើលនៅក្នុងរឿងក្តីជាច្រើនដូចជាបញ្ហាដែលលេចឡើងជាក្បួនខ្នាតនៅក្នុងប្រព័ន្ធច្បាប់ ឧទាហរណ៍ ការខកខានរបស់តុលាការមិនបានលើកហេតុផលយកមកសំអាងឱ្យបានសមស្របចំពោះសេចក្តីសំរេចរបស់តុលាការស្តីពីការឃុំខ្លួនមុនការវិនិច្ឆ័យក្តី។ របាយការណ៍ទាំងនេះប្រហែលជា ត្រូវរៀបរាប់ឧទាហរណ៍ឱ្យបានច្រើនពីតុលាការផ្សេងៗ ត្នាក៏ប៉ុន្តែប្រហែលអាចមានទំហំវែងជាងប្រាំទំព័រ។

- របាយការណ៍ដែលសង្ខេបពីភស្តុតាង និងគូសបញ្ជាក់ពីកង្វល់ដែលបានសង្កេតមើលនៅក្នុងរឿងក្តីដោយឡែកណាមួយ ឧទាហរណ៍ការវាយតម្លៃសរុបអំពីរឿងក្តីឧក្រិដ្ឋកម្មសង្គ្រាមមួយដែលបានចប់សព្វគ្រប់ហើយ។ របាយការណ៍អំពីរឿងក្តីទាំងនេះ ជាទូទៅ រួមមានពត៌មានជាប្រវត្តិដូចជាការចោទប្រកាន់ ប្រវត្តិនីតិវិធី និងសាលក្រមក៏ដូចជាកង្វល់អំពីការវិនិច្ឆ័វិនិច្ឆ័ក្តីដោយត្រឹមត្រូវយុត្តិធម៌ និងការវិភាគដែរ។ ដូច្នេះ របាយការណ៍ទាំងនេះអាចជារបាយការណ៍ ដែលមាន ទំហំវែងពី ១០ ដល់ ៤០ ទំព័រ។ ចូរមើលរបាយការណ៍ស្តីពីកម្មវិធីសង្កេតការណ៍ប្រព័ន្ធតុលាការដែលមានមូលដ្ឋាននៅទីម័យខាងកើតៈរឿងក្តី The Lolotoe Case: ការរីកចំរើនមួយដំណាក់តូច ខែកក្កដា ឆ្នាំ ២០០៤ អាចមានក្នុង http://www.jsmp.minihub.org. reports.html ឬរបាយការណ៍ដែលចេញដោយផ្នែកសង្កេតការណ៍ប្រព័ន្ធច្បាប់នៃអង្គការសន្តិសុខនិងសហប្រតិបត្តិការអឺរ៉ូបដែលមានមូលដ្ឋាន

នៅទីក្រុងកូសូវ៉ូ: រឿងក្តី The Llapi Case ថ្ងៃទី១៧ ខែធ្នូឆ្នាំ ២០០៣ ចូរបើកមើលក្នុង http://www.osce.org/kosovo/d-ocuments.html.

របាយការណ៍ស្តីពីកិច្ចចាត់ការរបស់តុលាការចំពោះរឿងក្តីឬបញ្ហាប្រភេទជាក់លាក់នានា ឧទាហរណ៍ថាតើតុលាការចាត់ការករណីបំភិតបំភ័យសាក្សីដោយរបៀបណាចូរមើលរបាយការណ៍នៃផ្នែកសង្កេតការណ៍ ប្រព័ន្ធច្បាប់/អង្គការសន្តិសុខ និងសហប្រតិបត្តិការអឺរ៉ូបស្តីពីកិច្ចការពារសាក្សីនៅក្នុងប្រព័ន្ធយុត្តិធម៌ឧក្រិដ្ឋកម្ម ខែមេសា ឆ្នាំ ២០០៣ ឬ រឿងក្តីឧក្រិដ្ឋកម្មសង្គ្រាមចូរមើលរបាយការណ៍ជាប្រវត្តិស្តីពី បេសកកម្មនៃអង្គការសន្តិសុខ និងសហប្រតិបត្តិការអឺរ៉ូប នៅក្រូអាទីៈការវិនិច្ឆ័យឧក្រិដ្ឋកម្មសង្គ្រាមនៅតុលាការក្នុងស្រុក ឆ្នាំ ២០០៤ ចុះថ្ងៃទី ២៦ ខែមេសាឆ្នាំ ២០០៥ អាចមាននៅ http://www.osce.org/croati /publica-tions.html.